# *រឿង មហាចោរនៅទល់ដែន*

***ភាគទី៧៤** (ជោគជ័យ)*

*ឱ! ស្រីអង្វរឲ្យទុកជីវិតនាង។*

*ចិត្តមួយទៀត គឺចិត្តស្នេហាការពារ ស្នេហាជាតិ។ ក្នុងការពារនេះនាងខត្តិយាណីជាឧបសគ្គមួយដ៏ធំក្រៃលែង។ បើលែងចោល កញ្ញានេះអាចរំលាយអង្គការតស៊ូបាន!*

*ចិត្តទាំងពីរនេះស្ថិតនៅក្នុងចិត្តមានន្ទតែមួយរួចច្បាំងគ្នាយ៉ាងគគ្រឹកគគ្រេង។ ត្រូវតែចិត្តមួយឈ្នះលើចិត្តមួយ។ ចិត្តទាំងពីរនេះ ពុំអាចនៅជាមួយគ្នាបានឡើយ។ ឥឡូវៈ ឬទុកជីវិតនាងទេវីទុំះជាតិវេទនា!! ឬសម្លាប់នាងមណី នាងទេវីសម្លាញ់ស្លាប់!!*

*ចំណែកនាងទេវីវិញ ពីរមុខរឿងនេះ តើស្រីគិតយ៉ាងណា?*

*នាងនឹកថាក្នុងមួយពេលនេះ បើមានន្ទសុខចិត្តអោយគេសម្លាប់នាងប្រុសនេះហៅចំជាប្រុសអាក្រក់មែន គ្មានចិត្តប្រុសឡើយ។ នាងនឹកទៀតថា ការតស៊ូមិនមែនប្តូរមនុស្សដូចប្តូរអាវនោះទេ គឺមានល្បិចបន្ថែម។ រីឯជីវិតមនុស្សថ្លៃណាស់។ ស្រីជ្រួញចិញ្ចើមស្រីឃើញថានាងស្លាប់ហើយ ស្រីឃើញថាមានន្ទប្តីសម្លាញ់នាងសម្លាប់នាង នឹងដៃឯងហើយព្រោះទឹកមុខមានន្ទប្រឹង។ បុរសប្រឹងគិតប្រឹងទាល់តែដល់ចុងបំផុត បញ្ញាជាតិមានជ័យជំនះលើសេចក្តីស្នេហ៍។ មានន្ទខាំធ្មេញជាសញ្ញាប្រាប់ថា សម្លាប់នាងមណី សុខចិត្តឲ្យគេសម្លាប់ទេវីពន្ធកចុះ។ ស្រីជាករិយាខឹងធ្លលឡើងណែនអស់ដើមទ្រូង។*

*តែពេលដដែលនោះ ព្រួញពីរត់ពីមាត់បង្អួចខាងនោះ ចូលមកត្រូវអ្នកចាប់នាងទេវីពឹប។ ទាហានស្រែកអូយៗដួលច្រងាង។ នាងទេវីស្ទុះរត់ទៅក្រៅ។*

*នាងមាលាដែលទើបនឹងបាញ់ព្រួញអម្បាញ់មិញនេះជាមួយស្ត្រីម្នាក់ទៀតក៏រត់ទៅខ្ទប់ទ្វារមិនឲ្យនាងទេវីដែលយំរហោមរត់រួចឡើយ។*

*នៅបង្អួចពីលើម្ខាងទៀត អារុណាយិតព្រួញតម្រង់ចុងដង្ហើមព្រះនាងខត្តិយាណី។ ព្រួញរត់ហេរមកបុកដើមទ្រូងនោះឮឌឹប។ ស្រីដួលតួងស្រែកថាៈ*

*អត្ថបទដោយៈ មាស សុភាព*

អូយ! អូយ!

មាននុក្រឡេកទៅលើឃើញវីរៈ មហាកាល និងមិត្តឯទៀតជាច្រើនមកដល់ដែរកំពុងតដៃវីកវាយជាមួយខ្មាំង។

ព្រះនាងមណីឈឺចុករមួលទាំងខ្លួនក្នុងរង្វង់ដៃមាននុ។ នាងនិយាយឡើង ខ្សាវៗថា:

បង! បង! ប្អូនសូមចងកម្ម...ចងពៀរវេរា...ជាមួយបងទៅជាតិមុខទៀត...សុំចង...ចង...ពៀរ...ពៀរ...

ឮដូច្នោះ មាននុងក់ក្បាលនិយាយថា:

បាទ! មិនអីទេ!

ធីតាក៏កម្រើកខ្លួនចុងក្រោយបំផុត ដើម្បីជូនសង្ខារស្រីឲ្យមច្ចុរាជវិញ។

នេះហើយ អំពើទុច្ចរិតដែលពីដើមធ្លាប់តែមានជ័យជន្នះ តែដល់ពេលមួយទុច្ចរិតតាមទាន់ជនអ្នកជាតួឯកដែលសប្បាយនឹងលេងល្បែងនេះរមែងតែងចាញ់មិនខាន។ អយុត្តិធម៌រស់បាន តែដោយសារមនុស្សប្រាសចាកការតស៊ូ ឬខ្លាចញញើតទេ។ ដរាបណាមនុស្សចេញចុះ ពុះពារដោយម៉ឺងម៉ាត់ហើយ ដរាបនោះសុចរិតធម៌ផុស ឡើងមិនយូរឡើយ។

ភស្តុតាង ព្រះនាងមណីដែលទើបនឹងដួលស្តូកស្តឹងស្លាប់ក្នុងថ្មុកឈាមអាក្រក់អម្បាញ់មិញនេះ។

មាននុក្រោកឡើងជួយប្រកាប់ប្រចាក់នឹងគេ រួចក្រឡេកមើលខាងឆ្វេងឃើញមហាកាលកំពុងតដៃជាមួយកាមា។ ក្រឡេកមើលស្តាំឃើញនាងទេវីកំពុងបម្រះចេញពីដៃនាងមាលារកផ្លូវរត់។

និលឯកយឺតធ្នូបាញ់នាងទេវីផ្ងង។ ព្រួញរត់ផាល់យ៉ាងលឿន។ មាននុស្រែក:

គេច! អូន!

**(សូមរង់ចាំតាមដានភាគទី៧៥ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព